# សេចក្តីសម្រេច

## ស្តីពីការកំណត់បញ្ជីថ្លៃលក់អគ្គិសនីតាមយន្តការកែតម្រូវថ្លៃលក់តាមថ្លៃប្រេងម៉ាស៊ូត ឱ្យសេវាករ ហៃ ទីណា ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ទូទៅ នៅទីរួមស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

## អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- អនុវត្តតាមការកំណត់របស់អនុក្រឹត្យ លេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី
- អាជ្ញាប័ណ្ណរួមលេខ១៦២.ឯអ ដែលបានចេញឱ្យលោក ហៃ ទីណា នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៧
- ឯកសារស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនីរបស់លោក ហៃ ទីណា ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩
- យោងឯកសារគណនា វិភាគ វាយតម្លៃរបស់នាយកដ្ឋានជំនាញនៃអាជ្ញាធរអគ្គិសនីកម្ពុជា
- យោងការពិគ្រោះយោបល់សាធារណៈ ចាប់ពីថ្ងៃទី២៥ ខែធ្នូ ដល់ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០
- យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជាលើកទី១៧៨ នាថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០

## សម្រេច

### ប្រការ ១ ៖

កំណត់បញ្ជីថ្លៃលក់អគ្គិសនីឱ្យសេវាករ ហៃ ទីណា កាន់អាជ្ញាប័ណ្ណលេខ១៦២.ឯអ ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ទូទៅ នៅទីរួមស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដោយកំណត់បញ្ជីថ្លៃលក់ជាតារាងប្រែប្រួលតាមថ្លៃប្រេងម៉ាស៊ូត ដែលមានកំណត់ដូចខាងក្រោម ÷

| | | | | | |
|---|---|---|---|---|---|
| ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន) | | 360 | 425 | 490 | 555 |
| ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉) | 2,300 | 2,400 | 2,500 | 2,600 | |
| ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន) | | 620 | 685 | 750 | 815 |
| ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉) | 2,700 | 2,800 | 2,900 | 3,000 | |
| ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន) | | 880 | 945 | 1,010 | 1,075 |
| ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉) | 3,100 | 3,200 | 3,300 | 3,400 | |

| | | | | | |
|---|---|---|---|---|---|
| ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន) | 1,140 | 1,205 | 1,270 | 1,335 | |
| ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉) | 3,500 | 3,600 | 3,700 | 3,800 | |
| ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន) | 1,400 | 1,465 | 1,530 | 1,595 | |
| ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉) | 3,900 | 4,000 | 4,100 | 4,200 | |
| ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន) | 1,660 | 1,725 | 1,790 | 1,855 | |
| ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉) | 4,300 | 4,400 | 4,500 | 4,600 | |

## ប្រការ ២ ៖

តារាងថ្លៃលក់ដែលប្រែប្រួលតាមថ្លៃប្រេងម៉ាស៊ូតខាងលើនេះ ត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌដែលមានកំណត់ដូចខាងក្រោម ៖

១- តារាងថ្លៃលក់ដែលប្រែប្រួលតាមថ្លៃប្រេងឥន្ធនៈនេះ គឺជាការកំណត់បញ្ជីថ្លៃលក់ជាចង្កោមមួយដែលប្រែប្រួលទៅតាមកម្រិតថ្លៃប្រេងឥន្ធនៈ។

២- ការប្តូរពីកម្រិតថ្លៃមួយទៅកម្រិតថ្លៃមួយទៀត នៅក្នុងប្រការ១ខាងលើ ត្រូវមានការសម្រេចឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីអាជ្ញាធរអគ្គិសនីកម្ពុជាអាចត្រួតពិនិត្យលើថ្លៃប្រេងឥន្ធនៈថាតើបានប្រែប្រួលត្រឹមត្រូវដែលអាចអនុញ្ញាតឱ្យប្តូរពីថ្លៃមួយទៅថ្លៃមួយទៀតបាន ឬទេ។

៣- នៅពេលដែលថ្លៃប្រេងម៉ាស៊ូតកើនឡើង ឬថយចុះជាក់ស្តែងដល់កម្រិតជាក់លាក់មួយដែលមានកំណត់នៅក្នុងតារាងនៃប្រការ១ អាជ្ញាធរអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណ ឬអ្នកប្រើប្រាស់មានសិទ្ធស្នើសុំកែសម្រួលអត្រាថ្លៃលក់ ពីកម្រិតមួយទៅកម្រិតមួយទៀតបាន។

៤- អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវពត៌មាន អំពីការប្រែប្រួលថ្លៃប្រេងម៉ាស៊ូតដែលរួមមានវិក្កយបត្រទិញប្រេងឥន្ធនៈពីប្រភពនានាជាក់ស្តែង។

៥- អាជ្ញាធរអគ្គិសនីកម្ពុជានឹងចេញលិខិតអនុញ្ញាតយល់ព្រម លើការស្នើសុំកែតម្រូវអត្រាថ្លៃលក់ក្នុងតារាងនៃប្រការ១ក្នុងរយៈពេលមិនហួស៣០ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំនិងទទួលបានឯកសារភ័ស្តុតាងគ្រប់គ្រាន់សម្រាប់ការកែសម្រួលកម្រិតថ្លៃលក់ក្នុងតារាងនេះ។ ការយល់ព្រមនេះមិនចាំបាច់ធ្វើការពិគ្រោះយោបល់សាធារណៈឡើយ។

## ប្រការ ៣ ៖

តារាងថ្លៃលក់ដែលប្រែប្រួលតាមថ្លៃប្រេងម៉ាស៊ូតមានចែងក្នុងប្រការ១ខាងលើ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ រហូតដល់មានការកែសម្រួលឡើងវិញ ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ស្របតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៤ ៖

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចំពោះអ្នកប្រើប្រាស់អគ្គិសនីគ្រប់ប្រភេទដែលឋិតក្នុងតំបន់ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីរបស់សេវាករ ហៃ ទីណា ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ទូទៅ នៅទីរួមស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ប៉ុណ្ណោះ។

**ប្រការ ៥ ៖**

សេវាករ ហៃ ទីណា និងអ្នកប្រើប្រាស់អគ្គិសនីគ្រប់ប្រភេទដែលឋិតក្នុងតំបន់ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីរបស់សេវាករ ហៃ ទីណា មានភារកិច្ចអនុវត្តតារាងបញ្ជីថ្លៃលក់អគ្គិសនីនេះឱ្យមានប្រសិទ្ធភាព។

**ប្រការ ៦ ៖**

សេវាករ ហៃ ទីណា មានភារកិច្ចផ្សព្វផ្សាយអំពីខ្លឹមសារសេចក្តីសម្រេចនេះ ដល់អតិថិជនរបស់ខ្លួនគ្រប់ប្រភេទដែលពាក់ព័ន្ធ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**<u>ចម្លងជូន</u> :**

- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- សាលាខេត្តព្រះវិហារ
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តព្រះវិហារ
- សាលាស្រុកជាំក្សាន្ត
- សាលាឃុំជាំក្សាន្ត

  “ដើម្បីជូនជ្រាប”
- សេវាករ ហៃ ទីណា

  “ដើម្បីផ្សព្វផ្សាយ និងអនុវត្ត”
- ឯកសារ-កាលប្បវត្តិ